សូមអញ្ជើញសិស្សម្នាក់ឲ្យអាន លូកា ១៨:១៨–២៣ ដោយរកមើលរបៀបដែលការឆ្លើយតបរបស់ ព្រិកហាំ យ៉ង់ ចំពោះការអញ្ជើញឲ្យបម្រើគឺខុសពីបុរសដែលបានប្រាស្រ័យទាក់ទងជាមួយនឹងព្រះអង្គសង្គ្រោះនៅក្នុងដំណើររឿងនេះ ។

- តើអ្នកដឹងអ្វីខ្លះអំពីព្រះអម្ចាស់ដែលអាចជួយយើងឲ្យមានឆន្ទៈធ្វើការលះបង់ដូចជា ព្រិកហាំ យ៉ង់ បានធ្វើ ?
- ក្រៅពីការបម្រើបេសកកម្ម តើព្រះអម្ចាស់អាចនឹងចង់ឲ្យយើងលះបង់អ្វីខ្លះដើម្បីបម្រើទ្រង់ ?

សូមចែកចាយអារម្មណ៍របស់អ្នកអំពីការមានឆន្ទៈលះបង់ដើម្បីបម្រើព្រះអម្ចាស់ ។

## ការពិភាក្សាទី ៣

**បេសកកម្មរបស់ ព្រិកហាំ ទៅប្រទេសអង់គ្លេស**

ចាប់ផ្ដើមដោយការសួរសំណួរដូចខាងក្រោម ៖

- តើមានមូលហេតុមួយចំនួនអ្វីខ្លះដែលអ្នកផ្សព្វផ្សាយសាសនាត្រូវការជំនួយពីព្រះអម្ចាស់ ?

សូមអាន ឬសង្ខេបដូចខាងក្រោមនេះ ៖

បន្ទាប់ពីបានរៀបការជាថ្មី និងបម្រើបេសកកម្មចំនួនប្រាំផ្សេងទៀត ព្រិកហាំ ត្រូវបានហៅជាមួយពួកសាវកដទៃទៀតដើម្បីបម្រើបេសកកម្មមួយទៅកាន់ប្រទេសអង់គ្លេស ។

ព្រិកហាំ បានរៀបរាប់អំពីបេសកកម្មរបស់លោកថា ៖



> យើងបានទៅដល់. . .ជាមនុស្សចំណូលថ្មី នៅលើទឹកដីថ្មីមួយ ហើយគ្មានលុយមួយរៀលសោះ ប៉ុន្តែតាមរយៈសេចក្ដីមេត្តាករុណារបស់ព្រះយើងបានមានមិត្តភក្ដិជាច្រើន បានបង្កើតសាសនាចក្រនៅស្ទើរគ្រប់ទីប្រជុំជន និងទីក្រុងនៅក្នុងចក្រភពអង់គ្លេស បានធ្វើបុណ្យជ្រមុជទឹកចន្លោះពីប្រាំពីរទៅ ប្រាំបីពាន់នាក់ បានបោះពុម្ពព្រះគម្ពីរមរមនចំនួន ៥,០០០ ក្បាល . . . ហើយបានសាបព្រួសនៅក្នុងដួងចិត្តរបស់មនុស្សរាប់ពាន់នាក់នូវគ្រាប់ពូជនៃសេចក្ដីពិតដ៏អស់កល្បជានិច្ច . . . ៖ នៅក្នុងដំណើររឿងទាំងអស់នេះខ្ញុំស្គាល់ពីស្នាព្រះហស្តរបស់ព្រះ ។ ( *Teachings of Presidents of the Church: Brigham Young* [ ឆ្នាំ ១៩៩៧ ] ទំព័រ ៦ )

សូមអញ្ជើញសិស្សម្នាក់ឲ្យអានពាក្យសម្ដីរបស់អាំម៉ូននៅក្នុងអាលម៉ា អាលម៉ា ២៦:១២–១៣ ។ បន្ទាប់មកសូមសួរ ៖

- តើសេចក្ដីថ្លែងការណ៍របស់ ព្រិកហាំ យ៉ង់ ប្រៀបធៀបទៅនឹងសេចក្ដីថ្លែងការណ៍របស់អាំម៉ូនដោយរបៀបណា ?
- អ្នកគិតថា ហេតុអ្វីការពឹងផ្អែកលើព្រះអម្ចាស់គឺចាំបាច់នៅពេលខិតខំដើម្បីបម្រើទ្រង់ ?
- តើអ្នកបានព្យាយាមពឹងផ្អែកលើព្រះអម្ចាស់យ៉ាងដូចម្ដេចពេលអ្នកបម្រើទ្រង់ ?

សូមចែកចាយគំនិត ឬអារម្មណ៍របស់អ្នកអំពីការពឹងផ្អែកលើព្រះអម្ចាស់ពេលអ្នកបម្រើទ្រង់ ។

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© 2024 by Intellectual Reserve, Inc. All rights reserved. PD80007812_258_441-1